





## លទ្ធផលស្រាវជ្រាវជាគន្លឹះពីឆ្នាំ ១៩៩៩ ដល់ ២០០៤

វាជាការច្បាស់លាស់ណាស់ ដោយយោងទៅតាមប្រភពពត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ដែលផ្តល់ដោយរបាយការណ៍ត្រួតពិនិត្យគ្រាប់មីនឆ្នាំ២០០៤ ដែលជាសន្ធិសញ្ញាលុបបំបាត់គ្រាប់មីននិងចលនាលុបបំបាត់មីន ជាទូទៅ បានវិវត្តន៍ឈានឡើងយ៉ាងឆាប់រហ័ស ក្នុងដំណើរការលុបបំបាត់គ្រាប់មីន និងជួយស្រោចស្រង់ជីវិតនិងអវះយវៈអ្នករងគ្រោះគ្រប់តំបន់ទូទាំងពិភពលោក ។ តែទោះជាយ៉ាងណាក្តីក៏កិច្ចពុះពារដ៏គួរអោយធុញថប់ដែលនៅសេសសល់ត្រូវធ្វើនោះគឺ ការធ្វើសកលភាវូបនីយកម្មសន្ធិសញ្ញាលុបបំបាត់មីននិងពង្រឹងគោលការលុបបំបាត់មីន បោសសំអាតមីនអោយអស់ពីផ្ទៃដី បំផ្លាញគ្រាប់មីនអោយអស់ និង ជួយឧបត្ថម្ភអ្នករងគ្រោះដោយសារមីន។ ក្រុមយុទ្ធនាការអន្តរជាតិលុបបំបាត់មីនជឿជាក់ថាវិធានការណ៍ពិតប្រាកដតែមួយគត់ដែលធ្វើអោយសិន្ធិសញ្ញាលុបបំបាត់គ្រាប់មីនអាចទទួលជោគជ័យបាននោះ គឺការធ្វើអោយឥទ្ធិពលជាក់ស្តែងរបស់សិន្ធិសញ្ញា គ្របដណ្តប់លើបញ្ហាមីនប្រឆាំងមនុស្សទាំងស្រុងបាន។ ដូចក្នុងរបាយការណ៍ ប្រចាំឆ្នាំចំនួនប្រាំឆ្នាំកន្លងមកដែរ របាយការណ៍ត្រួតពិនិត្យគ្រាប់មីនឆ្នាំ២០០៤ ផ្តល់មធ្យោបាយក្នុងការវាស់វែងឥទ្ធិពលនៃសិន្ធិសញ្ញាលុបបំបាត់គ្រាប់មីននេះ។ កំឡុងពេលធ្វើរបាយការណ៍ត្រួតពិនិត្យគ្រាប់មីនឆ្នាំ២០០៤គឺចាប់ពីខែឧសភាឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤។ អ្នកចងក្រងរបាយការណ៍ទាំងឡាយបានបំពេញបន្ថែមនូវពត៌មានសំខាន់ៗ ដែលប្រមូលបានចន្លោះពីខែមិថុនាដល់ ខែកញ្ញា ឆ្នាំ២០០៤ថែមទៀត ។ បន្ថែមពីនេះចំនុចគួសបញ្ជាក់ថា ពិសេសខួប៥ចន្លោះពីឆ្នាំ១៩៩៩ ជាឆ្នាំដែលសិន្ធិសញ្ញាលុបមំបាត់គ្រាប់មីនបានចូលជាធរមានមកដល់បច្ចុប្បន្នត្រូវបានបញ្ចូលបំពេញ សំរាប់ការបោពុម្ពផ្សាយឆ្នាំទីមួយនេះ។

**សូចនាករគន្លឹះចាប់ពីប្រាំឆ្នាំមុន (Key Indicators)**

- ប្រទេសចំនួន ១៥២បានយល់ព្រមហាមប្រាមការប្រើប្រាស់គ្រាប់មីន ប្រឆាំងមនុស្ស ។
- គ្រាប់មីនប្រឆាំងមនុស្ស ចំនួន ៦២ លានគ្រាប់ ត្រូវបានបំផ្លាញចោល រាប់បញ្ចូលទាំង ៣៧.៣ លានគ្រាប់ត្រូវបានបំផ្លាញដោយភាគីប្រទេស សន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។
- ផ្ទៃដីជាង ១.១០០ គីឡូម៉ែត្រក្រឡា ត្រូវបានបោសសំអាតចាប់ពី ឆ្នាំ១៩៩៩ ដោយបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្សជាង៤លានគ្រាប់ គ្រាប់មីនប្រឆាំងយានយន្តជិត ១ លានគ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជា ច្រើនលានប្រភេទផងដែរ ។
- ប្រទេសម្ចាស់ជំនួយបានផ្តល់ទឹកប្រាក់ជាង ១.៣៥ ពាន់លានដុល្លារ ដល់សកម្មភាពមីន ពីឆ្នាំ ១៩៩៩ - ២០០៣ និង ផ្តល់ទឹកប្រាក់ប្រហែល ២.១ ពាន់លានដុល្លារ ចាប់ពីឆ្នាំ ១៩៩២ មក ។
- ប្រជាជនប្រហែល ២២.៩ លាននាក់ បានចូលរួមក្នុងការសិក្សាអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មីន រវាងពីឆ្នាំ ១៩៩៩ ដល់ ២០០៣ ។

- ពីឆ្នាំ ១៩៩៩ ដល់ខែ កញ្ញា ២០០៤ អ្នកត្រួតពិនិត្យគ្រាប់មីនបានកត់ត្រាអំពីករណីគ្រោះថ្នាក់ដោយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង ដោយគ្រាប់មីនថ្មីៗជាង ៤២.៥០០ ករណី ដែលកើតឡើងដោយឧប្បត្តិហេតុយ៉ាងហោចណាស់នៅក្នុង ៧៥ ប្រទេស ។ យ៉ាងណាក៏ដោយ ករណីគ្រោះថ្នាក់ជាច្រើនបានកើតឡើងដោយមិនបានធ្វើរបាយការណ៍ ហើយចំនួនគ្រោះថ្នាក់ទាំងស្រុងពិតជាបានកើតឡើងខ្ពស់ជាងនេះខ្លាំងប្រហែលពី១៥.០០០ ទៅ ២០.០០០ ករណី ថ្មីៗក្នុងមួយឆ្នាំ។
- ប្រទេសដែលនៅបន្តប្រើប្រាស់គ្រាប់មីនក្នុងអំឡុងឆ្នាំ ១៩៩៩ ដល់ ២០០៤ មានប្រទេសរុស្ស៊ី និង សហភាពមីយ៉ាន់ម៉ា (ភូមា) ។
- មិនមានការទទួលស្គាល់ជាសាធារណៈអំពីការធ្វើពាណិជ្ជកម្មគ្រាប់មីនប្រឆាំងមនុស្សជាលក្ខណៈស្របច្បាប់ឡើយ ។

✓ *ការរាលដាលជាអន្តរជាតិអំពីការឈប់ប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស*

ប្រទេសសរុបចំនួន ១៤៣ ប្រទេស គឺជាភាគីប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ហើយប្រទេសចំនួន ៩ ផ្សេងទៀតបានចុះហត្ថលេខារួចហើយ ប៉ុន្តែមិនទាន់ដល់សច្ចាប័ន ដែលសរុបមានចំនួន ៣/៤ នៃប្រទេសក្នុងពិភពលោក ជាប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។ ចាប់តាំងពីការផ្តល់របាយការណ៍ពីពេលមុនរបស់អ្នកត្រួតពិនិត្យគ្រាប់មីនមក ប្រទេស ៩ ដែលបានចូលរួមក្នុងសន្ធិសញ្ញានេះ រួមមានប្រទេស ប៊ូរុនឌី (Burundi) និង ប្រទេសស៊ូដង់ (Sudan) ដែលប្រទេសទាំងពីរនេះបានរងគ្រោះដោយសារគ្រាប់មីន និង ប្រទេស បេឡារុស (Belarus) ប្រទេសក្រិច (Greece), ប្រទេសស៊ែកប៊ី (Serbia) និងប្រទេសម៉ុងតេនេក្រូ (Montenegro) ហើយនិងប្រទេសទួរគី (Turkey) ដែលសរុបបញ្ចូលគ្នាមានគ្រាប់មីនប្រឆាំងមនុស្សជាង ១០ លានគ្រាប់ ដែលត្រូវបំផ្លាញចោល ។ ប្រទេសមួយចំនួនដទៃទៀតបានចាត់វិធានការខ្លាំងក្លា សំដៅចូលរួម និង ត្រៀមខ្លួនផ្តល់សច្ចាប័ន រួមមាន : ប្រទេសប្រ៊ុយណេ, ប្រទេស Latvia, ប្រទេសប៉ូឡូញ និង ប្រទេស Vanuatu ។

✕ *ការពុះពារអោយមានសកលភាវូបនីយកម្ម*

ការពិតដែលមានតែប្រទេសពីរតែប៉ុណ្ណោះបានចូលរួមក្នុងសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ពីខែ វិច្ឆិកា ២០០៣ ដល់ខែ កញ្ញា ២០០៤ ទោះបីជាមានការកើនឡើងនូវកិច្ចខំប្រឹងប្រែងសកលភាវូបនីយកម្ម លើផ្នែកនិមួយៗរបស់រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលនានា សំដៅចូលរួមក្នុងកិច្ចប្រជុំកំពូលក្នុងទីក្រុង Nairobi គឺជាការរំខានមួយ ។ ប្រទេសចំនួន ៤២ ដែលមានគ្រាប់មីនប្រឆាំងមនុស្ស បញ្ចូលគ្នាប្រហែល ១៨០-១៨៥ លានគ្រាប់ នោះ នៅតែស្ថិតនៅក្រៅសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនដដែល ។ ប្រទេសទាំងនោះរួមមាន : សមាជិកអចិន្ត្រៃយ៍ ៣ ក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទាំង ៥ (ចិន, រុស្ស៊ី និង សហរដ្ឋអាមេរិក) ភាគច្រើននៃប្រទេសក្នុងតំបន់មជ្ឈឹមបូពា ភាគច្រើននៃប្រទេសអតីតសាធាណរដ្ឋសូវៀត និង ប្រទេសនៅអាស៊ីច្រើនទៀត ។ នៅខែកុម្ភៈ ២០០៤ សហរដ្ឋអាមេរិកបានបោះបង់ចោលគោលដៅដែលបានប្រឹងប្រែងយូរអង្វែងរបស់ខ្លួន ក្នុងការលុបបំបាត់ចោលការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សទាំងអស់ជាយថាហេតុ ។ រដ្ឋាភិបាលហ្វាំងឡង់បានជូនដំណឹងនៅក្នុងខែកញ្ញា ឆ្នាំ ២០០៤ ថា ពួកគេនឹងមិនចូលរួមក្នុងសន្ធិសញ្ញាលុបបំបាត់មីននេះរហូតដល់ឆ្នាំ២០១២ គឺនៅជាងប្រាំមួយឆ្នាំក្រោយទៀតគេជាគោលដៅដំបូងដែលពួកគេបញ្ចេញអោយដឹង។

✓ *ប្រទេសកាន់តែតិចទៅប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស*

ការធ្លាក់ចុះ ដែលបានកត់ត្រាទុកក្នុងការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សនៅជុំវិញសកលលោក ចាប់ពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៩០ គឺគ្មានបញ្ហាក្នុងការសំរេចបាននូវសមិទ្ធផលឧត្តុង្គឧត្តមនៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន និង ចលនាបញ្ឈប់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សជាទូទៅបន្ថែមទៀត ។ អ្នកត្រួតពិនិត្យគ្រាប់មីន បានអះអាងអំពីការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ដោយប្រទេសចំនួន ១៦ នៅតាមតំបន់មួយចំនួនចាប់ពីឆ្នាំ ១៩៩៩ ហើយមានការចងក្រងភស្តុតាងដែលថា ប្រទេស ៥ ទៀត បានប្រើប្រាស់គ្រាប់មីននេះ ។ ក្នុងការក្រលេកមើលនិន្នាការ

របាយការណ៍អ្នកត្រួតពិនិត្យគ្រាប់មីន ឆ្នាំ ១៩៩៩ បានបង្ហាញអោយឃើញអំពីការប្រើប្រាស់គ្រាប់មីនដែលបានអះអាង ឬ ទំនងជាបានប្រើប្រាស់គ្រាប់មីនដោយប្រទេសចំនួន ១៥ ក្នុងឆ្នាំ ១៩៩៨/១៩៩៩ រីឯរបាយការណ៍អ្នកត្រួតពិនិត្យគ្រាប់មីន ឆ្នាំ ១៩៩៤ បានបង្ហាញអោយឃើញប្រទេសចំនួន ៤ ដែលបានប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សនៅឆ្នាំ ២០០៣/២០០៤។

✕ *ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សដោយប្រទេសមិនមែនសមាជិកសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន*

ប្រទេសដែលបានប្រើប្រាស់គ្រាប់មីនជាបន្តបន្ទាប់ក្នុងកំឡុងឆ្នាំ ១៩៩៩-២០០៤ មានប្រទេសរុស្ស៊ី និង សហភាពមីយ៉ាន់ម៉ា (ភូមា) ។ ជាងនេះទៀត ប្រទេស Eritrea, ឥណ្ឌា, អ៊ីរ៉ាក់, អ៊ីស្រាអែល, Kyrgyzstan, នេប៉ាល់, ប៉ាគីស្ថាន, ស្រីលង្កា, អ៊ូបេគីស្ថាន និង ប្រទេសយូហ្គូស្លាវី បានសារភាពអំពីការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សក្នុងកំឡុងពេលនោះ អ្នកត្រួតពិនិត្យគ្រាប់មីនក៏បានរកឃើញផងដែរថា ប្រទេស Georgia បានដាក់ពង្រាយគ្រាប់មីនប្រឆាំងមនុស្សនៅក្នុងឱកាសមួយចំនួន ប៉ុន្តែរដ្ឋាភិបាលបានបដិសេធអំពីបញ្ហានេះ ។ ប្រទេសពីរក្នុងចំណោមប្រទេសនេះ បានក្លាយជាសមាជិកសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន គឺប្រទេស Eritrea នៅខែ កុម្ភៈ ២០០២ និងប្រទេស Serbia និងប្រទេស Montenegro (អតីតសាធារណរដ្ឋសហព័ន្ធយូហ្គូស្លាវី) នៅខែ មិនា ២០០៤ ។

✕ *ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សដោយប្រទេសហត្ថលេខី និង សមាជិកសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន*

អ្នកត្រួតពិនិត្យគ្រាប់មីនមិនបានរកឃើញភស្តុតាងជាក់លាក់ណាមួយអំពីការប្រើប្រាស់គ្រាប់មីន ដោយប្រទេសហត្ថលេខីណាមួយឡើយ ប៉ុន្តែមានការបញ្ជាក់អះអាងដែលអាចយកជាការបាន និង ជាក់ស្តែងមួយចំនួន ទាក់ទងនឹងប្រទេស Uganda នៅឆ្នាំ ២០០០ ។ ប្រទេស Angola, ប្រទេស Ecuador, ប្រទេស Ethiopia និងប្រទេស Venezuela បានទទួលស្គាល់ថាបានប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស បន្ទាប់ពីបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ប៉ុន្តែមុនពេលដែលក្លាយជាប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន និងមានការអះអាងជាក់ស្តែងបន្ថែមទៀតអំពីការប្រើប្រាស់គ្រាប់មីន ដោយប្រទេសហត្ថលេខី ៣ ផ្សេងទៀត គឺប្រទេស Burundi, ប្រទេស Rwanda និងប្រទេសស៊ូដង់ ដែលប្រទេស ទាំងអស់នេះឥឡូវបានក្លាយជាប្រទេសសមាជិកសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។

✕ *ក្រុមអ្នកប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ដែលមិនមែនជាប្រទេស*

អ្នកត្រួតពិនិត្យគ្រាប់មីនបានរកឃើញថា យ៉ាងហោចណាស់មានក្រុមមិនមែនជាប្រទេស (NSA) ចំនួន ៧០ក្រុម ដែលបានប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ចាប់ពីឆ្នាំ ១៩៩៩ មក ។NSA បានប្រើប្រាស់គ្រាប់មីនជាប្រក្រតីក្នុងប្រទេសភូមា, Burundi, ប្រទេស Chechnya, ប្រទេស Columbia, សាធារណរដ្ឋប្រជាធិបតេយ្យ Congo, ប្រទេសឥណ្ឌា, ប្រទេស នេប៉ាល់, ប្រទេសហ្វីលីពីន, ប្រទេសសូម៉ាលី, ប្រទេសស៊ូដង់ និង ប្រទេស Uganda ។ ការរីករាលដាលនៃការប្រើប្រាស់គ្រាប់មីនជាលក្ខណៈឧទ្ទាម ក្នុងប្រទេសស្រីលង្កា និង ប្រទេស Angola បានបញ្ឈប់ដោយមានកិច្ចព្រមព្រៀងសន្តិភាព និង កិច្ចព្រមព្រៀងឈប់បាញ់ក្នុងប្រទេសទាំងពីរនេះ ។ ពួកឧទ្ទាម និង ក្រុម NSA ដទៃទៀត បានប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សយ៉ាងហោចណាស់ក្នុងប្រទេស ១៦ នៅឆ្នាំ ២០០៣ និង ២០០៤ ។ ក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ អ្នកត្រួតពិនិត្យគ្រាប់មីនបានដកស្រង់ការប្រើប្រាស់គ្រាប់មីនរបស់ក្រុម NSA ជាលើកដំបូងក្នុងប្រទេស Bolivia, ប្រទេស Bhutan, ប្រទេសអ៊ីរ៉ាក់ និង ប្រទេស ប៉េរូ ។

✓ *ការផលិតគ្រាប់មីនបានថយចុះ*

ក្នុងចំណោមប្រទេសចំនួន ៥០ ដែលត្រូវបានដឹងថា បានផលិតគ្រាប់មីនប្រឆាំងមនុស្ស មានប្រទេសចំនួន ៣៦ បានលះបង់ជាផ្លូវការ និង បញ្ឈប់ការផលិតគ្រាប់មីន ។ ក្នុងចំណោមប្រទេសទាំងនេះ ក៏មានប្រទេស ៣ ដែលជាប្រទេសមិនមែនសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន គឺប្រទេស Finland,ប្រទេស Israel និងប្រទេសប៉ូឡូញ ។ ចាប់តាំងពីបានចាប់ផ្តើម ធ្វើរបាយការណ៍នៅឆ្នាំ ១៩៩៩ មក អ្នកត្រួតពិនិត្យគ្រាប់មីនបានដកប្រទេសទួរគី, ប្រទេស Serbia និងប្រទេស Montenegro ចេញពីប្រទេសផលិតគ្រាប់មីនរបស់ខ្លួន ។ ប្រទេស Egypt បានបញ្ជាក់ក្រៅផ្លូវការថា ខ្លួនបានបញ្ឈប់ការផលិតគ្រាប់មីននៅឆ្នាំ ១៩៩៨ ។ សហរដ្ឋអាមេរិកមិនបានផលិតគ្រាប់មីនប្រឆាំងមនុស្សទេ ចាប់ពីឆ្នាំ ១៩៩៧

មក ។ ប្រទេសកូរ៉េខាងត្បូងបានបញ្ជាក់ថា ចាប់ពីឆ្នាំ ២០០០ មក ខ្លួនមិនបានផលិតគ្រាប់មីនណាមួយឡើយ ។ មន្ត្រី ០១ រូប មកពីប្រទេសចិនបានបញ្ជាក់នៅខែ កញ្ញា ឆ្នាំ ២០០៣ ថា មិនមានការផលិតគ្រាប់មីនណាមួយកើតឡើងក្នុងប្រទេសខ្លួនឡើយ ។ ការផលិតគ្រាប់មីនប្រឆាំងមនុស្សប្រភេទមួយចំនួនដោយប្រទេសរុស្ស៊ី ត្រូវបានបញ្ឈប់ជាបន្តបន្ទាប់ ។

× *ការផលិតគ្រាប់មីននៅតែបន្ត*

អ្នកត្រួតពិនិត្យគ្រាប់មីន បានរកឃើញថាប្រទេសចំនួន ១៥ ជាប្រទេសអ្នកផលិតគ្រាប់មីនប្រឆាំងមនុស្ស ។ ប្រទេសនេប៉ាល់ត្រូវបានបន្ថែមចូលក្នុងបញ្ជីអ្នកផលិតគ្រាប់មីននៅឆ្នាំ ២០០៣ ដែលជាការបន្ថែមលើកទី ១ ចាប់តាំងពីរបាយការណ៍អ្នកផលិតគ្រាប់មីនបានចាប់ផ្តើមនៅឆ្នាំ ១៩៩៩ មក ។ ក្នុងករណីខ្លះ មិនមានភាពច្បាស់លាស់អំពីខ្សែសង្វាក់ផលិតកម្មគ្រាប់មីន មានលក្ខណៈប្រកាន់ដែរឬអត់ ក្នុងចន្លោះឆ្នាំ ១៩៩៩ និង ២០០៤ ។ អ្នកការទូតអ៊ីរ៉ាក់ម្នាក់បានបញ្ជាក់ថា ផលិតកម្មគ្រាប់មីននៅតែបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រាប់ទាំងក្នុងកំឡុងពេល ដែលនាំទៅរកសង្គ្រាមឈ្លានពាននៅឆ្នាំ ២០០៣ ប៉ុន្តែថា ឧបករណ៍ទាំងនេះត្រូវបានបំផ្លាញចោលក្នុងសង្គ្រាម ។ ប្រទេសឥណ្ឌា និង ប៉ាគីស្ថាន មានការពាក់ព័ន្ធខ្លាំងក្នុងផលិតកម្មគ្រាប់មីនប្រឆាំងមនុស្ស រួមទាំងប្រព័ន្ធបញ្ជាគ្រាប់មីនពីចម្ងាយថ្មីៗផងដែរ ។ មន្ត្រីនានាក្នុងប្រទេសសឹង្ហបុរី និង វៀតណាម បានទទួលស្គាល់ថា ផលិតកម្មគ្រាប់មីនប្រឆាំងមនុស្សនៅតែបន្ត ។ ប្រទេសភូមា, គុយបា និង កូរ៉េខាងជើង មិនបានអះអាងជាសាធារណៈ ឬ បដិសេធអំពីសកម្មភាពផលិតគ្រាប់មីនឡើយ ចាប់ពីឆ្នាំ ១៩៩៩ មក។

✓ *ការហាមប្រាមជាសកលតាមព្រឹត្តន័យលើការជួញដូរគ្រាប់មីនប្រឆាំងមនុស្ស*

ការហាមប្រាមជាសកលតាមព្រឹត្តន័យអំពីការផ្ទេរ ឬ នាំចេញគ្រាប់មីនប្រឆាំងមនុស្ស បានចូលជាធរមានចាប់ពីឆ្នាំ ១៩៩៦ មក ។ ពាណិជ្ជកម្មគ្រាប់មីនប្រឆាំងមនុស្សបានថយចុះបន្តិចម្តងៗ ទៅរកកំរិតមួយទាបបំផុតនៃការជួញដូរខុសច្បាប់ និង ពាណិជ្ជកម្មដែលគ្មានការទទួលស្គាល់ ។ ចំនួនប្រទេសក្រៅសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន បានអនុម័តច្បាប់ ឬ ពន្យាពេលការនាំចេញគ្រាប់មីនក្នុងរយៈពេល ៥ ឆ្នាំ កន្លងទៅ រួមមានប្រទេសចិន, ប្រទេសឥណ្ឌា, ប្រទេសអ៊ីស្រាអែល, ប្រទេស Kazakstan, ប្រទេសប៉ាគីស្ថាន, ប្រទេសប៉ូឡូញ, ប្រទេសរុស្ស៊ី, ប្រទេសសឹង្ហបុរី, ប្រទេសកូរ៉េខាងត្បូង និង សហរដ្ឋអាមេរិក ។ បន្ថែមលើនេះ តំណាងប្រទេសគុយបា, ប្រទេសអេហ្ស៊ីប និង ប្រទេសវៀតណាម បានអះអាងថាមិនបាននាំចេញគ្រាប់មីនប្រឆាំងមនុស្សឡើយ ប៉ុន្តែមិនមានការអនុវត្តន៏ការហាមប្រាមជាឯកតោភាគីផ្លូវការណាមួយឡើយ ។

✓ *គ្រាប់មីនប្រឆាំងមនុស្សរាប់លានគ្រាប់ត្រូវបានបំផ្លាញចោល*

នៅពេលដែលសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនត្រូវបានចរចារ និង ចូលជាធរមាន ប្រទេសចំនួន ១៣១ មានគ្រាប់មីនប្រឆាំងមនុស្ស ប្រមាណជាង ២៦០ លានគ្រាប់ ។ ក្នុងកំពុងពេលធ្វើរបាយការណ៍របស់អ្នកត្រួតពិនិត្យគ្រាប់មីននេះ គ្រាប់មីនប្រហែល ៤ លានគ្រាប់ត្រូវបានបំផ្លាញចោល ដែលចំនួននេះធ្វើអោយចំនួនគ្រាប់មីនសរុបទូទាំងសកលលោក ចំនួនប្រហែល ៦២ លានគ្រាប់ ត្រូវបានបំផ្លាញចោលក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ។ ភាគីប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនចំនួន ៦៥ ប្រទេស បានបញ្ចប់ការបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សជាង ៣៧,៣ លានគ្រាប់ ។ ប្រទេសអ៊ីតាលីបានបំផ្លាញចោលគ្រាប់មីនរបស់ខ្លួនច្រើនជាងគេ (៧,១ លានគ្រាប់) បន្ទាប់មកគឺប្រទេសទួរមេនីស្ថាន (៦,៦ លានគ្រាប់) ។ ប្រទេសអាល់បានី, ប្រទេសបារាំង, ប្រទេសអាល្លឺម៉ង់, ប្រទេសជប៉ុន, ប្រទេសរ៉ូម៉ានី, ប្រទេសស៊ុយអែត, ប្រទេសស្វីស និង ចក្រភពអង់គ្លេស ប្រទេសនីមួយៗបានបំផ្លាញគ្រាប់មីនប្រឆាំងមនុស្សជាងមួយលានគ្រាប់ ។

× *គ្រាប់មីនរាប់លានគ្រាប់ត្រូវបានប្រមូលទុកដោយប្រទេសមិនមែនសន្ធិសញ្ញាហាមប្រាមការ ប្រើប្រាស់គ្រាប់មីន*

គ្រាប់មីនប្រឆាំងមនុស្សចំនួនច្រើនបំផុតរវាងពី ១៨០ លាន ទៅ ១៨៥ លានគ្រាប់ ត្រូវបានរក្សាទុកដោយភាគីប្រទេសមិនមែនសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ។ ចំនួនភាគច្រើននៃគ្រាប់មីនស្តុកទុកទាំងនេះ ជារបស់

ប្រទេស ៣ គឺ ភាគីប្រទេសចិន (ប្រហែល ១១០ លានគ្រាប់) ប្រទេសរុស្ស៊ីប្រហែល ៥០ លានគ្រាប់ និង សហរដ្ឋអាមេរិក (ប្រហែល ១០,៤ លានគ្រាប់) ។ ប្រទេសដទៃទៀតដែលមានគ្រាប់មីនស្តុកទុកចំនួនច្រើន រួមមាន ប្រទេសប៉ាគីស្ថាន (ប្រហែល ៦ លានគ្រាប់) ប្រទេសឥណ្ឌា (ប្រហែល ៤ ទៅ ៥ លានគ្រាប់) និង ប្រទេសកូរ៉េខាងត្បូង (ប្រហែល ២ លានគ្រាប់) ។ ប្រទេសដទៃទៀតដែលមិនមែនជាភាគីសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ដែលគេជឿថាមានគ្រាប់មីនស្តុកទុកចំនួនច្រើន គឺប្រទេសភូមា, ប្រទេសអេហ្ស៊ីប, ប្រទេសហ្វាំងឡង់ដ៏, ប្រទេសអ៊ីរ៉ង់, ប្រទេសអ៊ីរ៉ាក់, ប្រទេសអ៊ីស្រាអែល, ប្រទេសស៊ីរី និង ប្រទេសវៀតណាម ។

✗ *ការខកខានមិនបានបំពេញលក្ខខ័ណ្ឌធ្វើរបាយការណ៍ប្រកបដោយតម្លាភាព*

ខណៈពេលដែលអត្រាប្រើប្រាស់គ្រាប់មីនសំរាប់ភាគីប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន ដែលបានដាក់ជូននូវរបាយការណ៍វិធានការប្រកបដោយតម្លាភាពដំបូង ដែលទាមទារដោយមាត្រា ៧ នៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន អាចទទួលយកបានប្រហែល ៩១% ភាគីប្រទេសសន្ធិសញ្ញានេះ ចំនួន ១២ មានការយឺតយ៉ាវក្នុងការដាក់ជូននូវរបាយការណ៍ ដូចជា : ប្រទេស Burundi, ប្រទេស Cape Verde, ប្រទេស សាធារណរដ្ឋអាហ្វ្រិកកណ្តាល, ប្រទេស Equatorial Guinea, ប្រទេស Guyana, ប្រទេស Liberia, ប្រទេស St. Lucia, ប្រទេស St. Vincent និង ប្រទេស Grenadines, ប្រទេស Sao Tome និង Principle, ប្រទេស Serbia និង Montenegro, ប្រទេស Sudan និងប្រទេស Turkey ។ ប្រទេស Equatorial Guinea (ត្រូវដាក់របាយការណ៍នៅថ្ងៃទី ២៨ ខែ សីហា ១៩៩៩), ប្រទេស St. Lucia (២៩ មិនា ២០០០), និងប្រទេស Liberia (២៨ សីហា ២០០០) អាចត្រូវបានចាត់ទុកជាប្រទេសដែលមិនបានអនុវត្តតាមកាតព្វកិច្ចតម្លាភាពនៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនខ្លាំងបំផុត ។ ប្រទេសទាំងបីនេះបានអនុម័តកាលបរិច្ឆេទចុងក្រោយរបស់គេ សំរាប់ការបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សទាំងឡាយ ប៉ុន្តែមិនបានជូនដំណឹងដល់ភាគីប្រទេសសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីន អំពីការអនុវត្តន៍តាមកាតព្វកិច្ចស្នូលនេះឡើយ ។

✗ *ការខកខានមិនបានយល់ដឹងអំពីអត្ថន័យនៃកាតព្វកិច្ចសន្ធិសញ្ញាជាគន្លឹះ*

ចាប់តាំងពីពេលដែលសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនបានចូលជាធរមាន ICBL បានលើកឡើងជាបន្តបន្ទាប់នូវបញ្ហាទាំងឡាយអំពីលក្ខណៈដែលប្រទេសសន្ធិសញ្ញានេះបកប្រែ និង អនុវត្តអត្ថន័យមួយចំនួននៃមាត្រា ១,២ និងមាត្រា ៣ ។ ជាពិសេស ICBL បានសំដែងនូវក្តីព្រួយបារម្ភ ទាក់ទងនឹងបញ្ហាប្រតិបត្តិការយោធារួមជាមួយប្រទេសមិនមែនសន្ធិសញ្ញា ការហាមឃាត់ក្នុងការ "ផ្តល់ជំនួយ" ការស្តុកទុកជាលក្ខណៈអន្តរជាតិ និង ការដឹកនាំគ្រាប់មីនប្រឆាំងមនុស្ស គ្រាប់មីនចំរុះគ្នា និង ឧបករណ៍ប្រឆាំងការប្រើប្រាស់ និង ចំនួនគ្រាប់មីនដែលបានអនុញ្ញាតអោយរក្សាទុកសំរាប់ការហ្វឹកហាត់ និង ដើម្បីក្នុងគោលបំណងអភិវឌ្ឍន៍ ។ICBL បានបញ្ជាក់ថា ប្រទេសភាគីសន្ធិសញ្ញាមួយចំនួន បានបកប្រែអត្ថន័យខុសពីច្បាប់ និង គោលការណ៍ប្រតិបត្តិអំពីបញ្ហានេះ ។

✓ *ការផ្តល់ជំនួយសកម្មភាពមីនកើនឡើង*

អ្នកត្រួតពិនិត្យគ្រាប់មីន បានបង្ហាញអំពីការផ្តល់វិភាគទានជំនួយក្នុងសកម្មភាពមីន មានទឹកប្រាក់ប្រហែល ២,០៧ ពាន់លានដុល្លារ ពីឆ្នាំ ១៩៩២-២០០៣ ។ ក្នុងចំនួនសរុបរយៈពេល ១២ ឆ្នាំ ទឹកប្រាក់ ៦៥% (១,៣៥ ពាន់លានដុល្លារ) ត្រូវបានផ្តល់អោយក្នុងរយៈពេល ៥ ឆ្នាំ កន្លងទៅ (១៩៩៩-២០០៣) ចាប់តាំងពីសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីននេះចូលជាធរមានមក ។ សំរាប់ឆ្នាំ ២០០៣ អ្នកត្រួតពិនិត្យគ្រាប់មីនបានរកឃើញទឹកប្រាក់ចំនួន ៣៣៩ លានដុល្លារ ក្នុងសកម្មភាពមីន ត្រូវបានផ្តល់អោយដោយប្រទេសម្ចាស់ជំនួយជាង ២៤ ប្រទេស ។ នេះជាចំនួនកើនឡើង ២៥ លានដុល្លារ ឬ ៨% ពីឆ្នាំ ២០០២ និង ចំនួនកើនឡើង ១០២ លានដុល្លារ ឬ ៤៣% ពីឆ្នាំ ២០០១ ។ ការកើនឡើងខ្លាំងត្រូវបានចុះបញ្ជីសំរាប់សហគមន៍អឺរ៉ុប និង សហរដ្ឋអាមេរិក ព្រមទាំងប្រទេសកាណាដា និង ស៊ុយអែត ។

✗ *ម្ចាស់ជំនួយថយចុះក្នុងការផ្តល់មូលនិធិសកម្មភាពមីន*

នៅឆ្នាំ ២០០៣ ការផ្តល់មូលនិធិសំរាប់សកម្មភាពមីនបានធ្លាក់ចុះគួរអោយកត់សំគាល់ សំរាប់ប្រទេសម្ចាស់ជំនួយសំខាន់ៗមួយចំនួន រួមមាន : ប្រទេសជប៉ុន, ប្រទេសអូទ្រីស, ប្រទេសអ៊ីតាលី, ប្រទេសអូស្ត្រាលី, ប្រទេសបារាំង និង ប្រទេសហូឡង់ ។

✓ *មូលនិធិដែលបានទទួលកើនឡើង*

ប្រទេសទទួលបានមូលនិធិខ្ពស់បំផុតសំរាប់កំឡុងពេល ៥ ឆ្នាំ (១៩៩៩-២០០៣) រួមមាន ប្រទេសអាហ្វហ្គានីស្ថាន (២០០ លានដុល្លារ), ប្រទេសអ៊ីរ៉ាក់ (១៤៩ លានដុល្លារ), ប្រទេសកម្ពុជា (១១៤ លានដុល្លារ), ប្រទេសកូសូវ៉ូ (៨៩ លានដុល្លារ), ប្រទេសអង់ហ្គោឡា (៨៤ លានដុល្លារ), ប្រទេស Bonia និង Herzegovina (៨២ លានដុល្លារ) និង ប្រទេស Mozambique (៧៣ លានដុល្លារ) ។ នៅឆ្នាំ ២០០៣ ការផ្តល់មូលនិធិសកម្មភាពមីនសំរាប់ប្រទេសអាហ្វហ្គានីស្ថាននៅបន្តកើនឡើង ដល់ ៧៥ លានដុល្លារ, ដែលសរុបរយៈពេល ២ ឆ្នាំ មានចំនួន ១៤១ លានដុល្លារ ។ មូលនិធិទាំងនេះត្រូវបានហូរចូលទៅប្រទេសអ៊ីរ៉ាក់ផងដែរ បន្ទាប់ពីសង្គ្រាមឈ្លានពាន និង ការបណ្តេញ សាដាម ហ៊ូសេន ចេញពីអំណាច ដោយមានចំនួនប្រហែល ៥៥ លានដុល្លារ នៅឆ្នាំ ២០០៣ ។ ប្រទេសស្រីលង្កា និង ប្រទេសស៊ូដង់ ក៏ជាប្រទេសអ្នកទទួលមូលនិធិច្រើនផងដែរ ។

✗ *តំរូវការមូលនិធិច្រើនបន្ថែមទៀត*

ចំនួនប្រទេសដែលទទួលរងគ្រោះដោយគ្រាប់មីនច្រើនបំផុតខុសប្រក្រតីមួយចំនួន បានទទួលនូវបទពិសោធន៍អំពីការបដិសេធមិនផ្តល់ជំនួយសំរាប់សកម្មភាពមីននៅឆ្នាំ ២០០៣ ។ ការផ្តល់ជំនួយសកម្មភាពមីន បានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ នៅឆ្នាំ ២០០៣ សំរាប់ប្រទេសវៀតណាម និង កម្ពុជា ប៉ុន្តែការធ្លាក់ចុះនេះក៏ត្រូវបានមើលឃើញផងដែរថាកើតមាននៅក្នុងប្រទេស Bosnia និង Herzegovina, ប្រទេស Eritrea, ប្រទេសដែនដីសូម៉ាលី, ប្រទេសឡាវ និង ប្រទេស Ethiopia ។ ប្រភពជំនួយសំរាប់ជនរសរានពីគ្រោះថ្នាក់ដោយសារគ្រាប់មីនត្រូវបានថយចុះចាប់ពីឆ្នាំ១៩៩៩មក ថ្វីបើចំនួនតំរូវការជួយអ្នកគ្រោះថ្នាក់មីននៅតែបន្តកើនឡើងរៀងរាល់ឆ្នាំក៏ដោយ ។

✓ *ការពង្រីកកម្មវិធីសកម្មភាពមីន*

បែបបទនៃសកម្មភាពបោសសំអាតគ្រាប់មីនមួយចំនួន ត្រូវបានរាយការណ៍ថាបានកើតឡើងនៅឆ្នាំ ២០០៣ និង ២០០៤ សរុប ៦៥ ប្រទេស និង ៧ តំបន់ រួមទាំងការបោសសំអាតគ្រាប់មីនសំរាប់គោលបំណងមនុស្សធម៌ ដែលបានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋស៊ីវិលក្នុងប្រទេស ចំនួន ៣៦ ។ ក្នុងកំឡុងពេលធ្វើរបាយការណ៍នេះ ប្រតិបត្តិការបោសសំអាតគ្រាប់មីនមនុស្សធម៌ បានចាប់ផ្តើមជាលើកដំបូងនៅប្រទេស Armenia (ខែ ឧសភា ២០០៣), ប្រទេស Chile (ខែ កញ្ញា ២០០៣), ប្រទេស Senegal (ចុងឆ្នាំ ២០០៣) និងប្រទេស Tajikistan (ខែ មិថុនា ២០០៤) ។ ចំនួនសរុបបញ្ចូលគ្នានៃផ្ទៃដីជាង ១៤៩ លានម៉ែត្រក្រឡា ត្រូវបានបោសសំអាតនៅឆ្នាំ ២០០៣ ដោយបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្សចំនួន ១៧៤.១៦៧ គ្រាប់, គ្រាប់មីនប្រឆាំងយានយន្ត ចំនួន ៩.៣៣០ គ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ ចំនួន ២,៦ លានគ្រាប់ ។

✓ *ភាគីប្រទេសសន្ធិសញ្ញាមួយចំនួនបានប្រកាសអំពីការបំពេញតាមកាតព្វកិច្ចបោសសំអាតគ្រាប់មីន*

ប្រទេសដែលបានប្រកាសអំពីការបញ្ចប់ការបោសសំអាតគ្រាប់មីន ចាប់ពីពេលបោះពុម្ពផ្សាយរបាយការណ៍ឆ្នាំ ១៩៩៩ របស់អ្នកត្រួតពិនិត្យគ្រាប់មីនមក រួមមាន : ប្រទេសប៊ុលហ្គារី (ខែ តុលា ១៩៩៩), ប្រទេស Moldova (ខែ សីហា ២000), ប្រទេស Costa Rica (ខែ ធ្នូ ២០០២), ប្រទេសសាធារណរដ្ឋឆែក (ខែ មេសា ២០០៣), ប្រទេស Djibouti (ខែ មករា ២០០៤) និង ថ្មីៗបំផុតនេះ គឺប្រទេស Honduras (ខែ មិថុនា ២០០៤) ។ នៅខែ មិថុនា ២០០៤

ប្រទេស Namibia បានបញ្ជាក់ថា ខណៈពេលដែលនៅតែមានបញ្ហាព្រំដែនជាមួយប្រទេស Angola ប្រទេសនេះអាចត្រូវបានមើលឃើញថាជាប្រទេសមានសុវត្ថិភាពគ្រាប់មីន ។

✕ *នៅតែមានប្រទេសដែលរងគ្រោះដោយគ្រាប់មីនច្រើនហើយមិនបានបំពេញការងារគ្រប់គ្រាន់*

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង គ្រាប់មីនបង្កប់ក្នុងដីដែលមិនបានបោសសំអាត ធ្វើអោយប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់ក្នុងប្រទេសចំនួន ៨៣ ប្រទេស ។ នៅឆ្នាំ ២០០៣ និង ២០០៤ មិនមានសកម្មភាពបោសសំអាតគ្រាប់មីនណាមួយត្រូវបានកត់ត្រានៅក្នុងប្រទេសចំនួន ២០ នៃប្រទេសទាំងនោះឡើយ រួមមានប្រទេសអាល់ហ្សេរី, ប្រទេសបង់ក្លាដេស, ប្រទេសប៊ូរុនឌី, សាធារណរដ្ឋកុងហ្គោ, ប្រទេសគុយបា, ប្រទេសដាណាម៉ាក, ប្រទេសបារាំង (Djibouti), ប្រទេសលីបេរីយ៉ា, ប្រទេសម៉ាឡាវី, ប្រទេសម៉ូរ៉ុកកូ, ប្រទេសនីហ្សេ (Niger), ប្រទេសកូរ៉េខាងជើង, ប្រទេសអូម៉ង់ (Oman), ប្រទេស Sierra Leone, ប្រទេសសូម៉ាលី, ប្រទេស Swaziland, ប្រទេសស៊ីរី, ប្រទេស Tunisia Uzbekistan និងប្រទេស Venezuela ។ នៅឆ្នាំ ២០០៣ និង ២០០៤ មិនមានសកម្មភាពអប់រំគ្រោះថ្នាក់អំពីគ្រាប់មីនត្រូវបានកត់ត្រាឡើយនៅក្នុងប្រទេសដែលរងគ្រោះដោយគ្រាប់មីន ចំនួន ២៣ ប្រទេស រួមទាំងប្រទេសភាគីសន្ធិសញ្ញាចំនួន ១៣ ប្រទេសផងដែរ ។

✓ *ជនរងគ្រោះដោយគ្រាប់មីនថ្មីៗមានចំនួនតិចតួចក្នុងប្រទេសមួយចំនួន*

ចំនួនករណីគ្រោះថ្នាក់ថ្មីៗដែលបានរាយការណ៍ បានធ្លាក់ចុះនៅឆ្នាំ ២០០៣ ពីឆ្នាំ ២០០២ ក្នុងចំនួនភាគច្រើននៃប្រទេសដែលរងគ្រោះដោយគ្រាប់មីន ក្នុងករណីខ្លះគួរអោយកត់សំគាល់ ដូចជា : ក្នុងប្រទេសអាហ្វហ្គានីស្ថាន, ប្រទេស Bosnia Herzegovina, ប្រទេសកម្ពុជា, ប្រទេសលីបង់, ប្រទេសសេនេហ្គាល់ និង ប្រទេសស្រីលង្កា ។

✕ *ជនរងគ្រោះដោយគ្រាប់មីនចំនួនច្រើន ត្រូវការជំនួយ*

សំរាប់ឆ្នាំ ២០០៣, អ្នកត្រួតពិនិត្យគ្រាប់មីន បានបង្ហាញអោយឃើញ ករណីគ្រោះថ្នាក់ថ្មីៗចំនួន ៨.០៦៥ ករណីដែលក្នុងនោះ ២៣% ជាកុមារ បានកើតឡើងក្នុងប្រទេសចំនួន ៦៥ ប្រទេស ។ បើប្រៀបធៀបទៅនឹងរបាយការណ៍អ្នកត្រួតពិនិត្យគ្រាប់មីនកាលពីឆ្នាំមុន មានប្រទេសថ្មីៗចំនួន ៤ បានរាយការណ៍អំពីករណីគ្រោះថ្នាក់កើតឡើងពីឧប្បត្តិហេតុទាក់ទងនឹងគ្រាប់មីន គឺប្រទេស Armenia, ប្រទេសបូលីវី, ប្រទេស Cyprus និង ប្រទេសលីបេរីយ៉ា ។ អ្នកត្រួតពិនិត្យគ្រាប់មីនបានអោយដឹងនូវចំនួនអ្នកដែលនៅមានជីវិតពីគ្រាប់មីនជាង ២៣០.០០០ នាក់ ត្រូវបានកត់ត្រាក្នុង ៩៧ ប្រទេស និង ៩ តំបន់ មួយចំនួនជាឧប្បត្តិហេតុដែលបានកើតឡើងនៅចុងសង្គ្រាមលោកលើកទី ២ ប៉ុន្តែ ចំនួនធំភាគច្រើននៃអ្នកនៅមានជីវិត គឺពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៧០ តទៅ ។ ដោយបានផ្តល់អោយនូវចំនួនខ្ពស់បំផុតនៃករណីគ្រោះថ្នាក់ដែលទំនងជាមិនដែលត្រូវបានកត់ត្រានោះ ជាមូលហេតុសមរម្យដើម្បីសន្និដ្ឋានថា មានអ្នកនៅមានជីវិតពីគ្រាប់មីន ចំនួនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ នៅកន្លែងណាមួយក្នុងពិភពលោកបច្ចុប្បន្ននេះ ។